# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១ សសរ

## សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតក្រុមការងាររបស់កម្ពុជា ដើម្បីរួមជាមួយក្រុមការងាររបស់ថៃ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំលើកទី២ រវាងអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ២៧៤ សជណផក របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៤
- យោងលិខិតលេខ ២០សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមងាររបស់កម្ពុជា ដើម្បីរួមជាមួយក្រុមការងាររបស់ថៃ ដើម្បីរួមគ្នារៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី២ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ព្រាំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម **ឆឹយ ឿន** អគ្គលេខាធិការរងរាជរដ្ឋាភិបាលកម្ពុជា អនុប្រធាន

៣-ឯកឧត្តម **សក់ សេដ្ឋា** អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ សមាជិកអចិន្ត្រៃយ៍

៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក **មៅ ចាន់តារ៉ា** អគ្គស្នងការរងនគរបាលជាតិ សមាជិក

៥-លោក **ឌាង ឡេងហួត** អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

៦-លោកឧត្តមសេនីយ៍ **ឈុំ សុជាតិ** មេបញ្ជាការទីចាត់ការព្រំដែន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

៧-លោក **ហែម សារឹម** ប្រធាននាយកដ្ឋានអាស៊ីទី១ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-លោកឧត្តមសេនីយ៍ **ចាន់ ស៊ាន** ប្រធាននាយកដ្ឋានព្រំដែនគោក អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

៩-លោកឧត្តមសេនីយ៍ **គៀត ចន្ទថារិទ្ធិ** ប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១០-លោកឧត្តមសេនីយ៍ **ឡៅ ស៊ុនហ៊ី** ប្រធាននាយកដ្ឋានព្រំដែនទឹក អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១១-លោកវរសេនីយ៍ឯក **សុខ សារ៉េត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក

១២-លោក **ញាណ ទិបុល** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក

១៣-លោក **ខាំ ពូនកែវមុនី** អ្នកបកប្រែ

**ប្រការ ២ :** ក្រុមការងារនេះមានភារកិច្ចពិភាក្សាសំរបសំរួលជាមួយក្រុមការងារថៃ ដើម្បីត្រៀមឱ្យកិច្ចប្រជុំលើកទី២ រវាងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ឱ្យបានលទ្ធផលល្អប្រសើរ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន